01573511

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារលេខ D304/6/4

# តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥៤)

**<u>អង្គបុរេជំនុំជម្រះ</u>**

| | |
|---|---|
| ចំពោះមុខ: | **ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន** |
| | **ចៅក្រម Olivier BEAUVALLET** |
| | **ចៅក្រម ន៉ីយ ថុល** |
| | **ចៅក្រម Kang Jin BAIK** |
| | **ចៅក្រម ហួត វុទ្ធី** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / 06 / 2018
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ**

## សេចក្តីសម្រេចលើសំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ

**<u>សហព្រះរាជអាជ្ញា:</u>**
ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តី អ៊ឹម ចែម:</u>**
ប៊ិត ស៊ាងលីម
Wayne JORDASH

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C.

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “សំណើរបស់ អ៊ឹម ចែម សុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់គាត់ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ”[1] និងឧបសម្ព័ន្ធ ក[2] ដែល អ៊ឹម ចែម បានដាក់ នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨ (“សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ”)។

## I. សេចក្តីផ្តើម

1. សហមេធាវីការពារក្តី អ៊ឹម ចែម ស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើចំណាត់ប្រភេទឡើងវិញនូវចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងគាត់ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង[3] ជាឯកសារសាធារណៈ ក្នុងលក្ខខណ្ឌធ្វើការកោសលុបដូចបានស្នើឡើងនៅក្នុងឧបសម្ព័ន្ធ ក របស់គាត់។ អ៊ឹម ចែម ក៏ស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើចំណាត់ប្រភេទសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់គាត់ ជាឯកសារសាធារណៈផងដែរ។

## II. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរប្រឆាំងនឹង អ៊ឹម ចែម តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ដោយស្នើសុំឱ្យបញ្ជូនគាត់ទៅជំនុំជម្រះ[4]។

---

[1] សំណុំរឿងលេខ ០០៤/១/០៧-០៩-២០០៩-អវតក/កសចស (“សំណុំរឿង ០០៤/១”) សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នៃចម្លើយតបរបស់អ្នកស្រី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨ ឯកសារ D304/6/1 (“សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ”)។

[2] សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នៃចម្លើយតបរបស់អ្នកស្រី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ឧបសម្ព័ន្ធ ក ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨ ឯកសារ D304/6/1.2។

[3] សំណុំរឿង ០០៤/១ ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D304/6 (“ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ”)។

[4] សំណុំរឿង ០០៤/១ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ D304/2 (“ដីកាសន្និដ្ឋានស្ថាពរ”)។

3. នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ សហមេធាវីការពារក្ដី អ៊ឹម ចែម បានផ្ញើលិខិតមួយច្បាប់ជូនសហចៅក្រមស៊ើបអង្កេត ស្នើឱ្យបដិសេធរាល់សំណើសុំដាក់អត្ថបទកោសល្យបសាធារណៈនៃដីកាសន្និដ្ឋានស្ថាពរ រហូតដល់ពេលចេញដីកាដំណោះស្រាយ[5]។ នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបទៅនឹងលិខិតខាងលើនេះ ដោយបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបដិសេធសំណើនៅក្នុងលិខិតនេះ[6]។

4. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ សហមេធាវីការពារក្ដីបានដាក់ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងគាត់ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង[7]។ នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយសម្ងាត់ (សំអាងហេតុ) ដោយបានលើកលែងរាល់ការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង អ៊ឹម ចែម និងអត្ថបទកោសល្យបសាធារណៈ[8]។

5. នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨ អ៊ឹម ចែម បានដាក់សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតប នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៨[9] ហើយ អ៊ឹម ចែម បានឆ្លើយតបវិញ នៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨[10]។

---

[5] សំណុំរឿង ០០៤/១ លិខិតមានចំណងជើងថា "អត្ថបទកោសល្យបសាធារណៈនៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា" ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ D304/3។

[6] សំណុំរឿង ០០៤/១ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងលិខិតរបស់ អ៊ឹម ចែម ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ស្ដីពីការដាក់ច្បាប់កោសល្យបជាសាធារណៈនៃដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ D304/3/1។

[7] ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ។

[8] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧ ឯកសារ D308/3។

[9] សំណុំរឿង ០០៤/១ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញរបស់ អ៊ឹម ចែម ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៨ ឯកសារ D304/6/2 ("ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ")។

[10] សំណុំរឿង ០០៤/១ ការឆ្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លើសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតបរបស់អ្នកស្រី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨



PRE-TRIAL CHAMBER E.C.C.C.

6. នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៨ អង្គបុរេជំនុំជម្រះបានចេញដីកាបង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលស្ថិតក្រោមវិធានការការពារ អនុលោមតាមវិធាន ២៩(៣) នៃវិធានផ្ទៃក្នុង[11]។ នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៨ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានចេញអនុស្សរណៈមួយ និងឧបសម្ព័ន្ធពីរ[12]។ នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៨ អង្គបុរេជំនុំជម្រះបានចេញដីកាបង្គាប់ឲ្យផ្តល់ព័ត៌មាន ពាក់ព័ន្ធនឹងបុគ្គលស្ថិតក្រោមវិធានការការពារ ក្នុងសំណុំរឿង ០០៤/០១[13] ហើយសហចៅក្រមស៊ើបអង្កេតបានឆ្លើយតបនៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨[14]។

## III. ភាពអាចទទួលយកបាន

7. សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញត្រូវបានដាក់ ស្របតាមមាត្រា ៩.១ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង[15] ព្រមទាំងមាត្រា ៣.១២

---

ឯកសារ D304/6/3 ("ការឆ្លើយតបរបស់ អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ")។

[11] សំណុំរឿង ០០៤/១ ដីកាបង្គាប់ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៨ ឯកសារ D309/2/1/5។

[12] សំណុំរឿង ០០៤/១ អង្គភាពគាំពារជនរងគ្រោះ និងអ្នកជំនាញ៖ ការវាយតម្លៃអំពីហានិភ័យ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៨ ឯកសារ D309/2/1/5/1 ព្រមទាំងឧបសម្ព័ន្ធ D309/2/1/5/1.1 និង D309/2/1/5/1.2។

[13] សំណុំរឿង ០០៤/១ ដីកាបង្គាប់លើកទីពីរពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៨ ឯកសារ D309/2/1/6។

[14] សំណុំរឿង ០០៤/១ ចម្លើយតបទៅនឹងដីកាបង្គាប់របស់អង្គបុរេជំនុំជម្រះ នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៨, ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៨ ឯកសារ D309/2/1/6/1 ព្រមទាំងឧបសម្ព័ន្ធ I និងឧបសម្ព័ន្ធ II។

[15] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០០៤/២០០៩/វិ.លើកទី ២ ស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង មាត្រា ៩.១។

និងមាត្រា ៣.១៤ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក[16]។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញអាចទទួលយកបាន។

## IV. អង្គសេចក្ដី

### ក. សារណា

8. សហមេធាវីការពារក្ដី អ៊ឹម ចែម អះអាងថា ថ្វីត្បិតតែភាពសម្ងាត់នៃកិច្ចស៊ើបសួរមិនបានបញ្ឈប់ការអនុវត្ត ត្រឹមពេលបិទបញ្ចប់កិច្ចស៊ើបសួរក៏ដោយ[17] ក៏ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញនូវចម្លើយតបរបស់ពួកគេ ទៅនឹងដីកាសន្និដ្ឋានស្ដាពរ ត្រូវបានធានាដោយផលប្រយោជន៍យុត្តិធម៌ ដើម្បីធានាតម្លាភាពនៃកិច្ចដំណើរការនីតិវិធី និងផ្ដល់ជូនសាធារណជននូវការយល់ឃើញមួយដែលមានគោលដៅថ្លឹងថ្លែងព័ត៌មាន "មិនត្រឹមត្រូវ និងបំភាន់" ដែលមាននៅលើអ៊ីនធឺណិត[18]។ សហមេធាវីការពារក្ដី អ៊ឹម ចែម សង្កត់ធ្ងន់បន្ថែមទៀតថា ព័ត៌មានដែលសាធារណជនអាចរកមើលបានមានសេចក្ដីយោងតិចតួចណាស់ទៅលើអំណះអំណាងរបស់មេធាវីការពារក្ដី ពាក់ព័ន្ធនឹងបញ្ហានានាដែលមាននៅក្នុងដីកាសន្និដ្ឋានស្ដាពរ[19]។ អាស្រ័យហេតុនេះ សហមេធាវីការពារក្ដីស្នើសុំឱ្យចេញអត្ថបទសាធារណៈនៃចម្លើយតបរបស់ពួកគេ ទៅនឹងដីកាសន្និដ្ឋានស្ដាពរ ក្នុងលក្ខខណ្ឌធ្វើការកោសលុប ដូចបានស្នើនៅក្នុងឧបសម្ព័ន្ធ ក[20]។ ជាចុងក្រោយ សហមេធាវីការពារក្ដី អ៊ឹម ចែម ជូនដំណឹងថា ពួកគេនឹងស្វះស្វែងស្នើសុំឱ្យធ្វើចំណាត់ប្រភេទឡើងវិញ នូវឯកសារទាំងអស់ដែលបានដាក់នៅក្នុងសំណុំរឿង ០០៤/០១ "នាពេលឆាប់ៗ"[21]។

---

[16] សេចក្ដីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិ.លើកទី ៨ ស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក មាត្រា ៣.១២ និងមាត្រា ៣.១៤។

[17] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់ អ៊ឹម ចែម កថាខណ្ឌ ១៤។

[18] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់ អ៊ឹម ចែម កថាខណ្ឌ ១៨-១៩។

[19] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់ អ៊ឹម ចែម កថាខណ្ឌ ២០។

[20] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់ អ៊ឹម ចែម កថាខណ្ឌ ១៧។

[21] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់ អ៊ឹម ចែម កថាខណ្ឌ ១៧។

9. សហព្រះរាជអាជ្ញាអន្តរជាតិគាំទ្រសំណើរបស់សហមេធាវីការពារក្តី អ៊ឹម ចែម ប៉ុន្តែ ក៏យល់ឃើញផងដែរថា ការកោសលុបដែលបានស្នើឡើង មានលក្ខណៈទូលំទូលាយពេក និងស្នើសុំធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ នូវប្រតិចារឹកសវនាការលើបណ្តឹងឧទ្ធរណ៍ "ឯកសារពាក់ព័ន្ធ" និងដីកាដំណោះស្រាយទាំងស្រុង (សំអាងហេតុ)[22]។ សហព្រះរាជអាជ្ញាអន្តរជាតិឆ្លើយតបវិញថា តម្លាភាពនៃកិច្ចដំណើរការនីតិវិធីទាមទារឲ្យមានសាធារណភាពនៃសារណាទាំងអស់របស់ភាគី ក៏ដូចជាសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ជាជាងអំណះអំណាងសម្រាំងយកតែល្អ ដែលសហមេធាវីការពារក្តី អ៊ឹម ចែម ចង់ឲ្យដាក់បង្ហាញជាសាធារណៈ។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់បន្ថែមទៀតថា សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ គួបផ្សំជាមួយគោលជំហររបស់សហមេធាវីការពារក្តីថា សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតស្តីពីអាកប្បកិរិយាឧក្រិដ្ឋរបស់ អ៊ឹម ចែម ត្រូវកោសលុប ដោយសារតែកង្វះយុត្តាធិការ អាចបណ្តាលឲ្យមាន "ទម្រង់នៃតម្លាភាពមួយដែលមានលក្ខណៈវៀចវេរ និងសម្រាប់តែម្ខាង"[23]។ លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាអន្តរជាតិសង្កេតឃើញមានភាពចម្រូងចម្រាសគ្នានៅក្នុងអំណះអំណាងរបស់សហមេធាវីការពារក្តី អ៊ឹម ចែម ពាក់ព័ន្ធនឹងភាពសម្ងាត់នៃកិច្ចស៊ើបសួរ និងគូសបញ្ជាក់ថា ទឡ្ហីករណ៍ដែលសហមេធាវីការពារក្តីបានលើកឡើងអនុវត្តចំពោះរាល់ឯកសារទាំងអស់ ហេតុដូច្នេះ ត្រូវធ្វើចំណាត់ប្រភេទឡើងវិញទាំងអស់ រួមទាំងដីកាដំណោះស្រាយ (សំអាងហេតុ) ផងដែរ[24]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យមានការកែប្រែ[25] ប៉ុន្តែ យល់ស្របជាមួយសហមេធាវីការពារក្តី អ៊ឹម ចែម ឲ្យរក្សាទុកឈ្មោះរបស់

---

[22] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ កថាខណ្ឌ ២៣។

[23] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ កថាខណ្ឌ ៤-៥។

[24] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ កថាខណ្ឌ ៨-៩។ អង្គបុរេជំនុំជម្រះកំពុងទទួលបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ថ្នាក់ឡើងវិញនៃដីកាដំណោះស្រាយ (ឯកសារ D309/2/1/2 អបជ ០៤/១/៥៩)។

[25] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ កថាខណ្ឌ ១៧-១៩។

អ៊ឹម ចែម និងសេចក្តីយោងទៅរកដីកាសន្និដ្ឋានស្ថាពរ និងឯកសារផ្សេងទៀតដោយមិនធ្វើការកោសលុប ក្នុងលក្ខខណ្ឌថាឯកសារទាំងនេះត្រូវធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ[26]។

10. នៅក្នុងការឆ្លើយតបរបស់ខ្លួន[27] សហមេធាវីការពារក្តី អ៊ឹម ចែម អះអាងថា ទឡ្ហីករណ៍ស្ទើរតែទាំងស្រុងរបស់សហព្រះរាជអាជ្ញាអន្តរជាតិមិនជាប់ពាក់ព័ន្ធទៅនឹងប្រធានបទ ដោយសារតែទឡ្ហីករណ៍ទាំងនេះមិននិយាយដល់ការស្នើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ឬការកោសលុបដែលបានស្នើឡើង។ សហមេធាវីការពារក្តីរំឭកថា សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានអនុញ្ញាតឱ្យស្នើសុំធ្វើចំណាត់ប្រភេទឡើងវិញនូវរាល់ឯកសារទាំងអស់ ប្រសិនបើខ្លួនយល់ឃើញថាចាំបាច់ និងព្រួយបារម្ភថា សាធារណជនអាចត្រូវបានផ្តល់ជូននូវការយល់ឃើញដោយលម្អៀង និងតែមួយជ្រុងទៅលើការចោទប្រកាន់[28]។ បន្ថែមលើនេះទៅទៀត សហមេធាវីការពារក្តី អ៊ឹម ចែម គូសបញ្ជាក់ថា សហព្រះរាជអាជ្ញាអន្តរជាតិប្រើប្រាស់ចម្លើយតបរបស់ខ្លួន ទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ដើម្បីរៀបចំសាជាថ្មីម្តងទៀតនូវសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនូវប្រតិចារឹកសវនាការ ដែលមិនអាចទទួលយកបាន ដោយហេតុថាអង្គបុរេជំនុំជម្រះធ្លាប់បានចេញសេចក្តីសម្រេចបិទផ្លូវតវ៉ាលើបញ្ហានេះរួចទៅហើយ។ ទន្ទឹមនឹងនេះ សហមេធាវីការពារក្តី អ៊ឹម ចែម កត់សម្គាល់ថាសហព្រះរាជអាជ្ញាអន្តរជាតិផ្តល់ទឡ្ហីករណ៍បន្ថែម ដើម្បីគាំទ្រដល់បណ្តឹងឧទ្ធរណ៍កំពុងរង់ចាំការសម្រេច ពាក់ព័ន្ធនឹងការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ)[29]។ លើសពីនេះទៅទៀត សហមេធាវីការពារក្តី អ៊ឹម ចែម អះអាងថា សហព្រះរាជអាជ្ញាអន្តរជាតិ

---

[26] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ កថាខណ្ឌ ២០។

[27] ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ។

[28] ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ៣-៦។

[29] ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ៧។

រិះគន់ទៅលើកោសលុបដែលពួកគេបានស្នើឡើង ប៉ុន្តែ ខកខានមិនបានស្នើសុំការកែប្រែជាក់លាក់ណាមួយឡើយ[30]។

## ខ. ការពិភាក្សា

11. អង្គបុរេជំនុំជម្រះនឹងដោះស្រាយសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នៃចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពរ ជាមុនសិន (១) បន្ទាប់មក នឹងពិចារណាលើសំណើតបសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញបន្ថែមទៀតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (២)។

### 1. សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៃចម្លើយតប របស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពរ

12. មាត្រា ៩.១ នៃសេចក្តីណែនាំស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង ចែងថា៖ "ឯកសារ ឬព័ត៌មានអាចត្រូវបានចាត់ប្រភេទសាឡើងវិញ (និងដាក់ទៅក្នុងផ្នែកនៃសំណុំរឿងដែលមានកម្រិតសម្ងាត់ខុសគ្នា) អនុលោមតាមបទបញ្ជារបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប"[31]។

13. លើសពីនេះទៅទៀត មាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីការដាក់ឯកសារនៅ អ.វ.ត.ក ចែងថា៖ "តាមករណីសមស្រប ទាល់តែមានការចេញដីកាដំណោះស្រាយ និងសេចក្តីសម្រេចប្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាដំណោះស្រាយ ទើបសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ត្រូវពិនិត្យពិចារណាថា តើចំណាត់ប្រភេទឯកសារដែលបានស្នើសុំនោះមានលក្ខណៈសមស្របដែរឬទេ ហើយបើសិនជាមិនសមស្របទេ ត្រូវធ្វើសេចក្តីសម្រេចថាតើចំណាត់ប្រភេទអ្វីទើបសមស្រប"[32]។

[30] ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ១០។

[31] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/00៤/២00៩/វិ.លើកទី ២ ស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង មាត្រា ៩.១។

[32] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/0១/២00៧/វិ.លើកទី ៨ ស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក មាត្រា ៣.១២។

## ក. សេចក្ដីសម្រេចស្ដីពីការធ្វើចំណាត់ប្រភេទឡើងវិញនូវចម្លើយតប របស់ អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ដាពរ

14. ក្នុងករណីនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញអំពីការយល់ស្របគ្នា រវាងសហមេធាវីការពារក្ដី អ៊ឹម ចែម និងសហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការធ្វើចំណាត់ប្រភេទឡើងវិញនូវចម្លើយតបរបស់មេធាវីការពារក្ដីទៅនឹងដីកាសន្និដ្ឋានស្ដាពរ ជាឯកសារសាធារណៈ[33]។

15. អង្គបុរេជំនុំជម្រះសូមរំឭកថា ជាគោលការណ៍ ឯកសារដែលដាក់ទៅអង្គបុរេជំនុំជម្រះ ជាឯកសារសម្ងាត់ រហូតដល់អង្គបុរេជំនុំជម្រះបានធ្វើការសម្រេចលើបញ្ហានោះ អនុលោមតាមមាត្រា ៥.១.ជ នៃសេចក្ដីណែនាំស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង[34]។ ទោះជាយ៉ាងនេះក្ដី អង្គបុរេជំនុំជម្រះអាចធ្វើចំណាត់ប្រភេទឡើងវិញ ជាឯកសារសាធារណៈ ដោយមានការកោសលុប ប្រសិនបើចាំបាច់ អនុលោមតាមមាត្រា ៤.ច មាត្រា ៩.២ និងមាត្រា ៩.៣ នៃសេចក្ដីណែនាំអនុវត្តដដែលនេះ[35]។

16. តាមស្ថានភាពបច្ចុប្បន្ននៃកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤/០១ អង្គបុរេជំនុំជម្រះយល់ឃើញថាសមស្រប ក្នុងការបង្គាប់ឲ្យធ្វើចំណាត់ប្រភេទឡើងវិញនូវចម្លើយតបរបស់មេធាវីការពារក្ដី ទៅនឹងដីកាសន្និដ្ឋានស្ដាពរ[36] ពីឯកសារសម្ងាត់ ទៅជាឯកសារសាធារណៈ។ ការធ្វើចំណាត់ប្រភេទឡើងវិញនេះក៏សមស្របផងដែរចំពោះសំណើនេះ[37] ចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅ

---

[33] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់ អ៊ឹម ចែម កថាខណ្ឌ ១៦, ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ កថាខណ្ឌ ១, ការឆ្លើយតបរបស់ អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ១។

[34] សេចក្ដីណែនាំអនុវត្ត អ.វ.ត.ក/០០៤/២០០៩/វិ.លើកទី ២ ស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង មាត្រា ៥.១.ជ។

[35] សេចក្ដីណែនាំអនុវត្ត អ.វ.ត.ក/០០៤/២០០៩/វិ.លើកទី ២ ស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង មាត្រា ៤.ច មាត្រា ៩.២ និងមាត្រា ៩.៣។

[36] ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ដាពរ។

[37] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់ អ៊ឹម ចែម។

នឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ[38] និងការឆ្លើយតបរបស់ អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ[39]។

*ខ. វិសាលភាពនៃការកោសលុបចម្លើយតបរបស់មេធាវីការពារក្ដី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ*

17. ថ្វីត្បិតតែភាគីឯកភាពគ្នាលើការធ្វើចំណាត់ប្រភេទឡើងវិញ នូវចម្លើយតបរបស់មេធាវីការពារក្ដីទៅនឹងដីកាសន្និដ្ឋានស្ថាពរក៏ដោយ ក៏ពួកគេមិនឯកភាពគ្នាលើវិសាភាពនៃការកោសលុបនោះទេ។ មេធាវីការពារក្ដីបានស្នើឱ្យធ្វើការកោសលុប ក្នុងឧបសម្ព័ន្ធ ក នៃសំណើ[40]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានស្នើសុំឱ្យធ្វើការកោសលុប តាមការយល់ឃើញរបស់ខ្លួនផងដែរ[41]។

18. មាត្រា ១.២ នៃសេចក្ដីណែនាំស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង ចែងថា៖ "គោលការណ៍ដែលនាំឱ្យមានសេចក្ដីណែនាំអនុវត្តនេះគឺជាតម្រូវការទាមទារឱ្យមានតុល្យភាពរវាងការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និងផ្នែកផ្សេងៗនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ ដែលមិនបើកចំហដល់សាធារណជន តម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរដំណែល"[42]។

19. ក្រោយពីបានពិនិត្យមើលឧបសម្ព័ន្ធ ក និងពិចារណាលើទឡ្ហីករណ៍របស់ភាគី អង្គបុរេជំនុំជម្រះនឹងសម្រេចលើការកោសលុបទាំងបួនប្រភេទ ដែលមេធាវីការពារក្ដីបានស្នើឡើង។

---

[38] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ។

[39] ការឆ្លើយតបរបស់ អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ។

[40] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់ អ៊ឹម ចែម កថាខណ្ឌ ១៧។

[41] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ កថាខណ្ឌ ២៣។

[42] សូមមើលផងដែរ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សុំបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D193/5/5 កថាខណ្ឌ ១។

20. អង្គបុរេជំនុំជម្រះយល់ឃើញថាសមស្រប ក្នុងការរក្សាទុកឈ្មោះរបស់ អ៊ឹម ចែម ដោយមិនធ្វើការកោសលុប នៅក្នុងចម្លើយតបរបស់មេធាវីការពារក្តី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ។

21. អង្គបុរេជំនុំជម្រះក៏យល់ឃើញថាសមស្របផងដែរ ក្នុងការរក្សាទុកដោយមិនធ្វើការកោសលុបនូវរាល់ការយោងដល់ ឬការដកស្រង់ចេញពីសេចក្តីថ្លែងការណ៍របស់ អ៊ឹម ចែម ដែលបានដាក់នៅក្នុងសំណុំរឿង ០០៤/០១ ដោយសារតែឯកសារទាំងនេះស្ថិតនៅជាសាធារណៈរួចទៅហើយ។

22. បន្ថែមលើនេះទៀត អង្គបុរេជំនុំជម្រះយល់ឃើញថាមិនចាំបាច់កោសលុបឈ្មោះរបស់កម្មាភិបាលខ្មែរក្រហមដែលស្លាប់ទៅហើយ ដែលបានលើកឡើងនៅក្នុងចម្លើយតបរបស់មេធាវីការពារក្តី ទៅនឹងដីកាសន្និដ្ឋានស្ថាពរ នោះទេ។

23. ចំពោះការកោសលុបភស្តុតាងទាំងអស់ ដែលប្រមូលបានពីសាក្សី ឬពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការសំខាន់បំផុតក្នុងការធានាបាននូវសុវត្ថិភាពរបស់ជនរងគ្រោះ និងសាក្សី។ ពាក់ព័ន្ធនឹងលិខិតឆ្លើយឆ្លងខាងលើ រវាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះយល់ឃើញថាសមស្រប ក្នុងការកោសលុបតែឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលនីមួយៗ ដែលស្ថិតក្រោមវិធានការការពារ អនុលោមតាមវិធាន ២៩(៣) ឬដែលបានស្នើសុំវិធានការការពារ។

## 2. សំណើតបសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញបន្ថែមទៀតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ

24. ក្នុងចម្លើយតបរបស់ខ្លួនទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ដែលបានពិនិត្យមើលខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិស្នើតបទៅវិញសុំឱ្យធ្វើចំណាត់ប្រភេទឡើងវិញនូវប្រតិចារឹកសវនាការលើបណ្តឹងឧទ្ធរណ៍ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ១១ និងថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ឯកសារពាក់ព័ន្ធទាំងអស់ដែលបានដាក់ និងដីកាដំណោះស្រាយទាំងស្រុង (សំអាងហេតុ)[43]។

---

[43] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញ កថាខណ្ឌ ២ កថាខណ្ឌ ២៣។

25. មាត្រា ៣.១២ នៃសេចក្តីណែនាំស្តីពីការដាក់ឯកសារ ចែងថា៖ "អំឡុងពេលស៊ើបសួររបស់តុលាការ ភាគីដែលដាក់ឯកសារអាចស្នើសុំឱ្យដាក់ចំណាត់ប្រភេទឯកសារជាឯកសារសាធារណៈ ឬសម្ងាត់ ឬសម្ងាត់បំផុត អនុលោមតាមបទប្បញ្ញត្តិនៃសេចក្តីណែនាំស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង"[44]។ ជាដំបូង អង្គបុរេជំនុំជម្រះយល់ឃើញថា ចំណាត់ប្រភេទឯកសារណាមួយឡើងវិញ ត្រូវបានធ្វើឡើង អាស្រ័យលើការសម្រេចរបស់អង្គបុរេជំនុំជម្រះ។ នីតិវិធីបែបនេះអាចត្រូវបានផ្តួចផ្តើមដោយភាគីដាក់ឯកសារ ប៉ុន្តែ មិនមែនជាការតម្រូវជាចាំបាច់នោះទេ។ម្យ៉ាងវិញទៀត ស្របតាមខ្លឹមសារនៃសេចក្តីណែនាំស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងពត៌មានទាក់ទងសំណុំរឿង តុលាការអាចចាត់ការ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន និងមានឆន្ទានុសិទ្ធិខ្ពស់លើបញ្ហានោះ។

26. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះនឹងពិចារណាថា អនុលោមតាមសេចក្តីណែនាំស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង តើវាជាការសមស្របដែរឬទេ ក្នុងការពិនិត្យមើលឡើងវិញលើប្រភេទបច្ចុប្បន្ននៃឯកសារពាក់ព័ន្ធមួយចំនួនតូចដែលបានដាក់ នៅពេលធ្វើកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៃសំណុំរឿង ០០៤/១។

*ក. ប្រតិចារឹកសវនាការ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១១ និងថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ និងឯកសារពាក់ព័ន្ធ*

27. ប្រការដែលថាសំណើរបស់ព្រះរាជអាជ្ញា ត្រូវបានតាក់តែងក្រោមទម្រង់ជាសំណើតបវិញនោះមិនរារាំងអង្គបុរេជំនុំជម្រះមិនឱ្យអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឯកសារដែលខ្លួនបានបង្កើត និងបានធ្វើចំណាត់ប្រភេទដោយផ្ទាល់នោះឡើយ។ អាស្រ័យហេតុនេះជាបឋម អង្គបុរេជំនុំជម្រះយល់ស្របតាមសំណើ ពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឯកសារ

---

[44] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិ.លើកទី ៨ ស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក មាត្រា ៣.១២។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ឡើងវិញដែលអង្គបុរេជំនុំជម្រះបានតាក់តែង។ សំណើនេះពាក់ព័ន្ធនឹងដីកាកំណត់កាលបរិច្ឆេទសវនាការ[45] និងការស្នើឡើងពីមុនរបស់ភាគី[46]។

28. ទាក់ទងនឹងចំណាត់ប្រភេទឡើងវិញនៃសវនាការអសាធារណៈ អង្គបុរេជំនុំជម្រះយល់ឃើញថា ការណ៍ដែលសវនាការប្រព្រឹត្តទៅជាអសាធារណៈ មិនមែនមានន័យថាប្រតិចារឹកទាំងនោះត្រូវស្ថិតនៅជាសម្ងាត់ជាស្វ័យប្រវត្តដែលសាធារណជនមិនអាចរកមើលបាននោះទេ។ ការគ្រប់គ្រងតុលាការ និងការធ្វើចំណាត់ប្រភេទឯកសារ មានចែងនៅក្នុងប្រភពគតិយុត្តិផ្សេងៗគ្នា សម្រាប់គោលបំណងខុសៗគ្នា។ ចំណាត់ប្រភេទឯកសារមានកំណត់នៅក្នុងសេចក្តីណែនាំអនុវត្តពាក់ព័ន្ធ[47] រីឯការរៀបចំសវនាការវិញមានចែងនៅក្នុងវិធានផ្ទៃក្នុង[48]។

29. ទោះបីជា ជាគោលការណ៍ សវនាការមានលក្ខណៈសម្ងាត់ចំពោះមុខអង្គបុរេជំនុំជម្រះ ស្របតាមវិធាន ៧៧ (៥) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏អង្គបុរេជំនុំជម្រះសូមគូសបញ្ជាក់ថា "ជាគោលការណ៍ ឯកសារ និងពត៌មានក្នុងចំណាត់ថ្នាក់ដូចខាងក្រោមជាឯកសារ និងព័ត៌មានសម្ងាត់ លើកលែងតែមានចំណាត់ថ្នាក់ផ្សេងពីនេះ ដោយសេចក្តីសម្រេចរបស់តុលាការ [...] ឯកសារទាំងនេះមានដូចជា៖ កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក និងការថតសម្លេង/រូបភាពនៃសវនាការ

[45] ដីកាកំណត់កាលបរិច្ឆេទសវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D308/3/1/19។

[46] សេចក្តីស្នើលម្អិតសម្រាប់សវនាកាផ្ទាល់មាត់ក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៧ ឯកសារ D308/3/1/14។ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៧ ឯកសារ D308/3/1/15; លិខិតរបស់មេធាវីអឹមចែមមានចំណងជើងថាចម្លើយតបនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីសវនាការអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D308/3/1/16។ ការប្រាស្រ័យទាក់ទងរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០៤/១ មានចំណងជើងថាសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ(សំអាងហេតុ)ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D308/3/1/17។

[47] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០០៤/២០០៩/វិ.លើកទី២ ចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង។

[48] វិធាន៧៧ (៥និង៦) នៃវិធានផ្ទៃក្នុង។

*ជាសម្ងាត់*"[49]។ ហេតុនេះ សេចក្តីសម្រេចលើចំណាត់ប្រភេទឯកសារនៃប្រតិចារឹកសវនាការ*អសាធារណៈ*មិនមែនជាសេចក្តីសម្រេចស្ថាពរឡើយ ដោយហេតុថា ការធ្វើចំណាត់ប្រភេទឯកសារ អាចត្រូវកែប្រែទៅតាមសេចក្តីសម្រេចណាមួយទៀតរបស់តុលាការ។ វាដូចគ្នាដែរចំពោះចំណាត់ប្រភេទនៃខ្សែអាត់សម្លេង/រូបភាពនៃសវនាការទាំងនេះ[50]។

*ខ. ការដាក់ឯកសារពីសំណាក់សហមេធាវីតំណាងឱ្យអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី*

30. ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញក៏ទាក់ទងផងដែរទៅនឹងពាក្យសុំដែលពីដំបូងដាក់ដោយសហមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានតួនាទីក្នុងកិច្ចដំណើរការនីតិវិធី[51]។ បញ្ហានេះ ត្រូវបានលើកឡើងត្រួសៗដោយភាគីនាពេលកន្លងមក។ អង្គបុរេជំនុំជម្រះបដិសេធសំណើនេះ ហើយស្នើសុំឱ្យសហមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដាក់សារណាដែលមានការកម្រិត[52]។ សហមេធាវីរបស់ អ៊ឹម

---

[49] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០០៤/២០០៩/វិ.លើកទី២ ចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងសំណុំរឿង មាត្រា៥.១។

[50] ខ្សែអាត់សម្លេង និងរូបភាពនៃសវនាការអង្គបុរេជំនុំជម្រះ ថ្ងៃទី ១១ និង ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកសារលេខ D308/3/1/19/1.1R and D308/3/1/19/2.1R។

[51] សំណុំរឿង០០៤/១ សំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិសុំពន្យាពេល និងការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលើដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/4។

[52] សំណុំរឿង០០៤/១ ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិសុំពន្យាពេល និងការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលើដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/5។ សំណុំរឿង០០៤/១ ការឆ្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិតបទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម (D308/3/1/5) ទៅនឹងសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិសុំពន្យាពេល និងការអនុញ្ញាតដាក់ចម្លើយតបទៅនឹង បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលើដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/6។ សំណុំរឿង០០៤/១ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម តបទៅនឹងសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ថែម បានឆ្លើយតបទៅនឹងសារណានេះ[53]។ ឯកសារទាំងនេះ ក៏ត្រូវចាត់ចំណាត់ប្រភេទឡើងវិញដែរ។

*គ. វិសាលភាពនៃការកោសលុប*

31. ដោយផ្អែកលើមូលហេតុដូចគ្នាដែលបានរៀបរាប់ខាងលើ[54] អង្គបុរេជំនុំជម្រះយល់ឃើញថា ជាការសមស្របដែលថាឯកសារដែលត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញទាំងនោះមានការកោសលុបឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលនីមួយៗ ដែលស្ថិតក្រោមវិធានការការពារ អនុលោមតាមវិធាន ២៩(៣) ឬដែលបានស្នើសុំវិធានការការពារ។

*ឃ. ឯកសារពាក់ព័ន្ធផ្សេងទៀត*

32. ទាក់ទងនឹងការចាត់ចំណាត់ប្រភេទឡើងវិញចំពោះ "ឯកសារពាក់ព័ន្ធ" ជាដំបូង អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិមិនទាន់បានស្នើសុំឲ្យធ្វើការចាត់ចំណាត់ប្រភេទទៅលើសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួននោះទេ ទោះបីជាមានការជូនដំណឹងនៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ដែលបានដាក់នៅថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ២០១៨[55] ក៏ដោយ។ នៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី ដោយពិចារណាទៅលើចេតនារបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងផលប្រយោជន៍នៃកិច្ចការរដ្ឋបាលដ៏ល្អរបស់អង្គ

---

ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/7។ សំណុំរឿង០០៤/១ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិសុំដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឲ្យដាក់សារណា ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/8។ សំណុំរឿង០០៤/១ សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីគោលជំហររបស់ អ.វ.ត.ក ក្នុងប្រព័ន្ធច្បាប់កម្ពុជា ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/9។

[53] សំណុំរឿង០០៤/១ ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អំពីគោលជំហររបស់ អ.វ.ត.ក ក្នុងប្រព័ន្ធច្បាប់កម្ពុជា ឯកសារ (D308/3/1/9) ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/18។

[54] សូមមើល កថាខណ្ឌ 23។

[55] ចម្លើយតបរបស់សហព្រះរាជអាជ្ញាតបទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ២៣។

ជំនុំជម្រះ

អង្គបុរេជំនុំជម្រះយល់ឃើញថាជាការសមស្របក្នុងការបង្គាប់ឲ្យធ្វើចំណាត់ប្រភេទឡើងវិញ ចំពោះសេចក្តីសន្និដ្ឋានស្ថាពរ[56] របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលជាផ្នែកមួយនៃការពិនិត្យមើលឡើងវិញដ៏ទូលំទូលាយអំពីចំណាត់ប្រភេទឯកសារដែលបានលើកឡើងដោយសំណើនេះ។

33. ចំពោះ "ឯកសារពាក់ព័ន្ធផ្សេងៗទៀត" អង្គបុរេជំនុំជម្រះយល់មិនច្បាស់អំពីអ្វីដែលសហព្រះរាជអាជ្ញាអន្តរជាតិ ចាត់ទុកថាជា "ឯកសារពាក់ព័ន្ធ" ហួសពីអ្វីដែលត្រូវបានពិនិត្យពិចារណា នៅក្នុងកថាខណ្ឌខាងលើ។ ដូច្នេះ អង្គបុរេជំនុំជម្រះបដិសេធ ឯកសារពាក់ព័ន្ធទាំងនេះ ។

*ង. ដីកាដំណោះស្រាយ (សំអាងហេតុ)*

34. ចំពោះសំណោកែប្រែនៃដីកាដំណោះស្រាយ (សំអាងហេតុ) អង្គបុរេជំនុំជម្រះបានទទួលរួចហើយតាមរយៈបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ឬតាមរយៈសំណើសុំ[57]។ ហេតុនេះដោយមានការឆ្លើយតបរួចហើយក្នុងកិច្ចដំណើរការនីតិវិធីផ្សេងៗ សំណើដែលបានបញ្ជាក់សាជាថ្មីនេះ[58] ចាត់ទុកជាមោឃៈ។

**យោងតាមសំអាងហេតុទាំងនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ ÷**

- **បង្គាប់**ឲ្យមេធាវីការពារក្តីដាក់ក្នុងរយៈពេលប្រាំពីរថ្ងៃ នូវសំណៅសាធារណៈនៃឯកសារដូច តទៅនេះ៖

[56] ចម្លើយតបរបស់សហព្រះរាជអាជ្ញាតបទៅនឹង សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ កថាខណ្ឌ ២។

[57] សេចក្តីសន្និដ្ឋានស្ថាពរ។

[58] សំណុំរឿង០០៤/១ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើការកោសលុបដីកាដំណោះស្រាយ (សំអាងហេតុ) ឬតាមជម្រើសផ្សេងពីនេះ សំណើសុំធ្វើចំណាត់ឡើងវិញនៃដីកាដំណោះស្រាយ (សំអាងហេតុ) ឯកសារ D309/2/1/2។

- ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពរ[59]។
- សំណើអ្នកស្រី អ៊ឹម ចែម ស្នើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ នៃចម្លើយតបរបស់អ្នកស្រី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ[60]។
- ការឆ្លើយតបរបស់ អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ លើសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់អ្នកស្រី[61]។
- ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យាពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ[62]។
- ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីជំហររបស់ អ.វ.ត.ក ក្នុងប្រព័ន្ធច្បាប់កម្ពុជា[63]។
- សេចក្តីស្នើលម្អិតសម្រាប់សវនាកាផ្ទាល់មាត់ក្នុងសំណុំរឿង ០០៤/១[64]។

---

[59] ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ។

[60] សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់ អ៊ឹម ចែម។

[61] ការឆ្លើយតបរបស់ អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ។

[62] ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យាពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយមានសំអាងហេតុ ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/5។

[63] សំណុំរឿង០០៤/០១ ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីគោលជំហររបស់ អ.វ.ត.ក ក្នុងប្រព័ន្ធច្បាប់កម្ពុជា ឯកសារ (D308/3/1/9) ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/18 ។

[64] សំណុំរឿង០០៤/០១, លិខិតរបស់សហមេធាវីរបស់ អ៊ឹម ចែម មានចំណងជើងថាសេចក្តីស្នើលម្អិតសម្រាប់សវនាការផ្ទាល់មាត់ក្នុងសំណុំរឿង ០០៤/១ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ D308/3/1/14។

- ចម្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ)[65]។

- **ណែនាំ**ឲ្យមេធាវីការពារក្តីធ្វើការកោសលុបក្នុងសារណាទាំងនេះតែឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលនីមួយៗ ដែលស្ថិតក្រោមវិធានការការពារ អនុលោមតាមវិធាន ២៩(៣) ឬដែលបានស្នើសុំវិធានការការពារ។

- **បង្គាប់ឲ្យ**សហព្រះរាជអាជ្ញាអន្តរជាតិដាក់ ក្នុងរយៈពេលប្រាំពីរថ្ងៃ នូវសំណៅសាធារណៈនៃ ឯកសារដូចតទៅ៖

  - សេចក្តីសន្និដ្ឋានស្ថាពរស្របតាមវិធាន៦៦ របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង អ៊ឹម ចែម[66]។

  - ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ[67]។

  - ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើសុំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[68]។

  - សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ)[69]។

---

[65] ចម្លើយតបទៅនឹងការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ ថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D308/3/1/15, D308/3/1/16។

[66] ដីកាសន្និដ្ឋានស្ថាពរ។

[67] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញ។

[68] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើសុំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/7។

- **ណែនាំឱ្យ**សហព្រះរាជអាជ្ញាអន្តរជាតិធ្វើការកោសលុបក្នុងសេចក្តីសន្និដ្ឋានទាំងនេះ តែឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលនីមួយៗ ដែលស្ថិតក្រោមវិធានការការពារ អនុលោមតាមវិធាន ២៩(៣) ឬដែលបានស្នើសុំវិធានការការពារ។

- **សម្រេច** ធ្វើចំណាត់ប្រភេទឯកសារខាងក្រោមឡើងវិញជាឯកសារសាធារណៈ ក្នុងលក្ខខណ្ឌធ្វើការកោសលុប៖

  - ដីកាកំណត់កាលបរិច្ឆេទសវនាការ[70]។

  - ប្រតិចារិកនៃសវនាការ ថ្ងៃទី ១១ និង ១២ ខែ ធ្នូ ឆ្នាំ ២០១៧[71]។

  - ខ្សែអាត់សម្លេង/រូបភាពនៃសវនាការ ថ្ងៃទី ១១ និង ១២ ខែ ធ្នូ ឆ្នាំ ២០១៧[72]។

  - សំណើរបស់សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំពន្យាពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ លើដីកាដំណោះស្រាយ (សំអាងហេតុ)[73]។

---

69 សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីសវនាការអង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៧ ឯកសារ D308/3/1/15។

70 សំណុំរឿង០០៤/១ ដីកាកំណត់កាលបរិច្ឆេទសវនាការរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ឯកសារ D308/3/1/19។

71 សំណុំរឿង០០៤/១ ប្រតិចារិកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ (អសាធារណៈ) ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកសារ D308/3/1/19/1.2។ សំណុំរឿង០០៤/១ ប្រតិចារិកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ (អសាធារណៈ) ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកសារ D308/3/1/19/2.1។

72 ខ្សែអាត់សម្លេង/រូបភាពនៃសវនាការ ថ្ងៃទី ១១ និង ១២ ខែ ធ្នូ ឆ្នាំ ២០១៧ ឯកសារ D308/3/1/19/1.1R និង D308/3/1/19/2.1R។

73 សំណុំរឿង០០៤/១ សំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិសុំពន្យាពេល និងការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលើដីកាដំណោះស្រាយ (សំអាងហេតុ) ដាក់ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/4។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

- ការឆ្លើយតបរបស់សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម[74]។

- សេចក្តីសម្រេចលើសំណើរបស់សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឱ្យដាក់សារណា[75]។

- សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីគោលជំហររបស់ អ.វ.ត.ក. ក្នុងប្រព័ន្ធច្បាប់កម្ពុជា[76]។

- ការប្រាស្រ័យទាក់ទងពីសំណាក់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៤/១[77]។

- **ប្រកាស** ទុកជាមោឃៈចំពោះសំណើសុំបង្គាប់ឱ្យចេញសំណៅដីកាដំណោះស្រាយដែលមានការកែប្រែ (សំអាងហេតុ) ក្នុងសំណុំរឿង ០០៤/១។

- **បដិសេធ** ផ្នែកដែលនៅសេសសល់ផ្សេងទៀតនៃសំណើនេះ។

---

[74] សំណុំរឿង ០០៤/១ ការឆ្លើយតបរបស់មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិសុំពន្យាពេល និងការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលើដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៧ ឯកសារ D308/3/1/6។

[75] សំណុំរឿង០០៤/១ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ ពាក់ព័ន្ធនឹងការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ និងការអញ្ជើញឱ្យដាក់សារណា ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ, D308/3/1/8។

[76] សំណុំរឿង០០៤/១ សារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីគោលជំហររបស់ អ.វ.ត.ក. ក្នុងប្រព័ន្ធច្បាប់កម្ពុជា ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៧ ឯកសារ D308/3/1/9។

[77] សំណុំរឿង០០៤/១ ការប្រាស្រ័យទាក់ទងពីសំណាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានចំណងជើងថា "សវនាការអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ (សំអាងហេតុ) ឯកសារ D308/3/1/17 ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០១៧។

អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៨**

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

**ប្រាក់ គឹមសាន** | **Olivier BEAUVALLET** | **ន័យ ថុល** | **Kang Jin BAIK** | **ហួត វុទ្ធី**